# The Training on Safe Delivery Application and e-Learning Platform in Kampong Cham Province



*Picture: Activities of the Trainers and Trainees in the SDA and e-Learning Platform training*

On January 17-19, 2022, IINeoC project and Kampong Cham Provincial Health Department (PHD) organized training on Safe Delivery Application and e-Learning platform. The training was conducted at Kampong Cham PHD and joined by midwives who work at health facilities in Kampong Cham Province. The participants learned how to use the Safe Delivery Application and NMCHC's e-Learning platform for their training tool and job-aid.

The Safe Delivery App is free and works offline to guide healthcare workers in basic emergency obstetric and newborn care. The e-learning platform contains videos and animated instructions to explain the practical procedures that midwives and healthcare workers can always refer to at any time, or as part of their training.

It is very important under the current situation to improve the quality of health services and to deliver necessary health care equitably. To establish multi-stakeholder e-learning platform and adopt it for Continuous Professional Development program is a very innovative and also sustainable approach for the professional training, especially with consideration of mitigating the impact of Covid-19.

# វគ្គបណ្ដុះបណ្ដាលស្ដីពីកម្មវិធីការសម្រាលកូនដោយសុវត្ថិភាព (Safe Delivery Application) និង វេទិកាការសិក្សាតាមបែបអេឡិកត្រូនិក (e-Learning platform) នៅខេត្តកំពង់ចាម



*Picture: The trainees' activities during the SDA and e-Learning Platform Training*

ចាំពីថ្ងៃទី 17-19 ខែមករា ឆ្នាំ 2022 គម្រោង IINeoC និងមន្ទីរសុខាភិបាលខេត្តកំពង់ចាម បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីកម្មវិធីការសម្រាលកូនដោយសុវត្ថិភាព (Safe Delivery Application) និង វេទិកាការសិក្សាតាមបែបអេឡិកត្រូនិក (e-Learning platform)។ វគ្គបណ្ដុះបណ្ដាលនេះធ្វើឡើងនៅខេត្តកំពង់ចាម និងមានការចូលរួមពីឆ្មបដែលធ្វើការនៅរាល់ស្ថាប័នសុខភាពសាធារណៈទាំងអស់ក្នុងខេត្តកំពង់ចាម។ សិក្ខាកាមទាំងអស់ដែលបានចូលរួម បានរៀនពីរបៀបប្រើប្រាស់កម្មវិធីការសម្រាលកូនដោយសុវត្ថិភាព និងវេទិកាការសិក្សាតាមបែបអេឡិកត្រូនិកនៃគេហទំព័ររបស់មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក (NMCHC) សម្រាប់ជាឧបករណ៍បណ្ដុះបណ្ដាល និងជំនួយការងាររបស់ពួកគេ។

កម្មវិធីការសម្រាលកូនដោយសុវត្ថិភាព (Safe Delivery App) គឺមិនគិតថ្លៃទេ ហើយដំណើរការរបស់វាគឺមិនត្រូវការអិនធើណិត ដើម្បីណែនាំបុគ្គលិកសម្រាប់ការសង្គ្រោះបន្ទាន់ជាមូលដ្ឋានផ្នែកសម្ភព និងការថែទាំទារកទើបកើត។ វេទិកាការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកមានវីដេអូ និងការណែនាំដែលមានចលនា រស់រវើកដែលពន្យល់អំពីនីតិវិធីជាក់ស្ដែង ដែលឆ្មប និងបុគ្គលិកថែទាំសុខភាពតែងតែអាចយកជាឯកសារយោងគ្រប់ពេលវេលា ឬជាផ្នែកមួយនៃការបណ្ដុះបណ្ដាលរបស់ពួកគេ។

វាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងស្ថានភាពបច្ចុប្បន្ននេះ ដើម្បីកែលម្អគុណភាពនៃសេវាសុខភាព និងការផ្តល់ការថែទាំសុខភាពចាំបាច់ដោយសមធម៌។ ការបង្កើតវេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកដែលមានភាគីពាក់ព័ន្ធច្រើន និងការសម្របខ្លួនវាសម្រាប់កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត គឺជាវិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិតនិ ប្រកបដោយនិរន្តរភាពសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសជាមួយនឹងការពិចារណាលើការកាត់បន្ថយផលប៉ះពាល់នៃ Covid-19 ។